# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ៥៩. សសរ

## សេចក្តីសម្រេច
### ស្តីពី
### ការបង្កើតក្រុមការងារបច្ចេកទេសដើម្បីជំរុញ និងលើកកម្ពស់ប្រតិបត្តិការ របស់ក្រុមហ៊ុនអាកាសចរណ៍ Cambodia Angkor Air

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសដើម្បីជំរុញ និងលើកកម្ពស់ប្រតិបត្តិការរបស់ក្រុមហ៊ុនអាកាសចរណ៍ **Cambodia Angkor Air** ដែលមានសមាសភាពដូចរាយនាមខាងក្រោម ÷

១- ឯកឧត្តម **តឹកវ៉េត សំរេច** រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

២- ឯកឧត្តម **សយ សុខាន់** អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អនុប្រធាន

៣- លោក **កែវ ស៊ីវន** ប្រធាននាយកដ្ឋានប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

៤- លោក **ម៉ាត់ សុវុឌ្ឍិ** អនុប្រធាននាយកដ្ឋានប្រតិបត្តិការ និងសុវត្ថិភាព ហោះហើរ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

៥- លោក **ទឹម ទិសារ៉ាល** អនុប្រធាននាយកដ្ឋានប្រតិបត្តិការ និងសុវត្ថិភាព ហោះហើរ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក ។

**ប្រការ ២ :** ក្រុមការងារបច្ចេកទេស មានភារកិច្ចដូចខាងក្រោម ÷

- សហការជាមួយក្រុមការងាររបស់ភាគីវៀតណាម ក្នុងការសម្របសម្រួល និងផ្តល់យោបល់ដល់ការរៀបចំឯកសារបច្ចេកទេស ដើម្បីដំណើរការក្រុមហ៊ុនអាកាសចរណ៍ **Cambodia Angkor Air** ឱ្យបានទាន់ពេលវេលា
- ត្រួតពិនិត្យការអនុវត្តបទដ្ឋានបច្ចេកទេស នៃដំណើរការប្រតិបត្តិការរបស់ក្រុមហ៊ុនអាកាសចរណ៍ **Cambodia Angkor Air**
- ពិនិត្យ និងផ្តល់យោបល់លើឯកសារបច្ចេកទេស និងធនធានចាំបាច់ ដើម្បីឱ្យក្រុមហ៊ុនអាកាសចរណ៍ **Cambodia Angkor Air** ដំណើរការតាមស្តង់ដារអន្តរជាតិ ។

**ប្រការ ៣ :** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អង្គភាពពាក់ព័ន្ធ ប្រធាន អនុប្រធាន និង សមាជិកនៃក្រុមការងារ ដូចមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ០៦ ឆ្នាំ ២០០៩*

**ឧបនាយករដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*